# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ៧០ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការកំណត់តំបន់គ្រប់គ្រង ក្នុងតំបន់ការពារធម្មជាតិ ទៅជាតំបន់ប្រើប្រាស់ដោយចីរភាព

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងបរិស្ថាន
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២០៨/០០៧ ចុះថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ២០០៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីតំបន់ការពារធម្មជាតិ
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការបង្កើត និងការកំណត់តំបន់ការពារធម្មជាតិ
- យោងតាមតម្រូវការចាំបាច់របស់រាជរដ្ឋាភិបាល។

## សម្រេច

**មាត្រា១ៈ**

ត្រូវបានកំណត់តំបន់គ្រប់គ្រង ក្នុងតំបន់ឧទ្យានជាតិ **បុទុមសាគរ** លើផ្ទៃដីទំហំ ៩.១៣៧ហិកតា (ប្រាំបួនពាន់ មួយរយ សាមសិបប្រាំពីរហិកតា) ទៅជាតំបន់ប្រើប្រាស់ដោយចីរភាព ស្ថិតនៅក្នុងភូមិសាស្ត្រខេត្តកោះកុង សម្រាប់ផ្តល់ជូនក្រុមហ៊ុន **ឋានសួគ៌ ចំកាត់** (PARADISE INVESTMENT Co., Ltd) ធ្វើការវិនិយោគអភិវឌ្ឍន៍លើវិស័យដំណាំកសិ-ឧស្សាហកម្ម ដែលមានទីតាំង និងនិយាមកាដូចមានក្នុងផែនទីភ្ជាប់នឹងលិខិតលេខ ២៦៤ សជណ ចុះថ្ងៃទី ០៤ ខែ មីនា ឆ្នាំ២០១១ជាឧបសម្ព័ន្ធ។

**មាត្រា២៖**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៣៖**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងបរិស្ថាន ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ និងអភិបាលនៃគណៈអភិបាលខេត្តកោះកុង ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែមេសា ឆ្នាំ២០១១

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

*កន្លែងទទួល:*

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី "ដើម្បីគោរពជូនជ្រាប"
- ដូចប្រការ ៣ "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ, កាលប្បវត្តិ

## ផែនទី ទីតាំងដីសម្បទាន សម្រាប់វិនិយោគអភិវឌ្ឍន៍ដាំដំណាំកសិ-ឧស្សាហកម្ម លើផ្ទៃដីទំហំ ៩ ១៣៥ហិកតា ក្នុងតំបន់ប្រើប្រាស់ដោយចីរភាព នៃឧទ្យានជាតិបុទុមសាគរ ខេត្តកោះកុង របស់ក្រុមហ៊ុនហាន់សុគីចំកាត់




Legend

- TranSou_Channel
- Road_Union
- Paddy field with villages
- Village garden crop
- Settlement
- Infrastructure (Airfield, factory etc.)
- Garden crop
- Field crop
- Paddy field
- Swidden agriculture (Slash and burn)
- Orchard
- Abandoned field covered by grass
- Grass Savannah
- Grassland (undifferentiated)
- Receding and Floating rice fields
- Marsh and swamp
- Flooded grassland
- Flooded shrub
- Flooded forest
- Degraded mangrove forest
- Mangrove forest
- Plantation (Rubber plantation)
- Forest plantation
- Abandoned field covered by shrub
- Shrubland (undifferentiated)
- Mixed forest from evergreen and deciduous species
- Dry Deciduous (Open) forest
- Bamboo and Secondary forests
- Woodland and scattered trees (C < 10%)
- Riparian forest
- Coniferous forest
- Deciduous forest
- Evergreen broad leafed forest
- Shrimp Fish farming and Salt pan
- Barren land
- Sand bank
- Rock outcrop
- Reservoir

| ID | Name | X_Coord | Y_Coord |
|---|---|---|---|
| 1 | A | 313252 | 1221178 |
| 2 | B | 324160 | 1221209 |
| 3 | C | 324175 | 1215804 |
| 4 | D | 321276 | 1213226 |
| 5 | E | 321699 | 1210661 |
| 6 | F | 321214 | 1210167 |
| 7 | G | 319278 | 1212371 |
| 8 | H | 317166 | 1212453 |
| 9 | I | 315137 | 1214534 |
| 10 | J | 309987 | 1214400 |
| 11 | K | 309973 | 1214856 |

ផែនទី និងនិយាមការនេះ ជាឯកសារ
ភ្ជាប់នឹងលិខិតលេខ ២៦៤ សជណក.កស
ចុះថ្ងៃទី ០៥ ខែ មីនា ឆ្នាំ ២០១១
ជ.រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

ហ្វាស់ លាស់

ផែនទី និងនិយាមការនេះ ជាឯកសារ
ភ្ជាប់នឹងលិខិតលេខ ១២៥ សរាក.បស្ក.អកព
ចុះថ្ងៃទី ០៥ ខែ មីនា ឆ្នាំ ២០១១
ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងបរិស្ថាន